ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

# បទបង្ហាញស្តីពី
# ការបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងទិសដៅបន្តឆ្នាំ ២០២៣ ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ

បង្ហាញដោយ៖ លោក អឿន ធារិទ្ធ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៣

# មាតិកា

សេចក្តីផ្តើម

I. សមិទ្ធផលសម្រេចបាន

II. បញ្ហាប្រឈម

III. មេរៀន និងបទពិសោធន៍

- ចំណុចខ្លាំង៖
- ចំណុចខ្វះខាត៖
- សំណូមពរ៖

សេចក្តីសន្និដ្ឋាន

# សេចក្តីផ្តើម

ការអភិវឌ្ឍជនបទ គឺជាសកម្មភាពដែលដើរតួនាទីយ៉ាងសំខាន់ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិ និងការកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ជនបទចម្រុះ ដែលជាសកម្មភាពប្រទាក់ក្រឡា និងអន្តរវិស័យ សំដៅកែប្រែទីជនបទ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋនៅជនបទឱ្យមានភាពប្រសើរឡើង។

ក្នុងនោះដែរ ការអភិវឌ្ឍសហគមន៍ គឺជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋាន។ ម៉្យាងទៀត ការងារអភិវឌ្ឍន៍សហគមន៍ គឺជាយន្តការគន្លឹះមួយ ដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ នៅមូលដ្ឋានសំដៅធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាឥរិយាបថ និងផ្នត់គំនិតរបស់សហគមន៍ជនបទ ដើម្បីឱ្យការអភិវឌ្ឍមួយមានភាពជាម្ចាស់ និងប្រកបដោយនិរន្តភាព។

# ផ្ដើម (ត)

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជានាយកដ្ឋានជំនាញ ដែលបានចូលរួមយ៉ាងសកម្មក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅជនបទ តាមរយៈការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងការបង្កើនសមត្ថភាពសហគមន៍ ដើម្បីកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍។

ក្នុងនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មានការិយាល័យចំណុះចំនួន ០៥ រួមមាន ការិយាល័យកិច្ចការទូទៅ ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន ការិយាល័យសន្តិសុខស្បៀង ការិយាល័យអប់រំក្រៅប្រព័ន្ធ និងការិយាល័យមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ព្រមទាំងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ។ ក្នុងឆ្នាំ ២០២២ នេះ នាយកដ្ឋានបានអនុវត្តការងារ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

# I. សមិទ្ធផលសម្រេចបាន

ក្នុងឆ្នាំ ២០២២ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ឋិតក្នុងកម្មវិធីទី៣ អនុកម្មវិធីទី ៤ គឺ ការជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ ទទួលបានថវិកាកម្មវិធីប្រចាំឆ្នាំសរុបចំនួន **៩០៧.២** លានរៀល។ ធៀបទៅនឹងផែនការថវិកាប្រចាំឆ្នាំសម្រេចបាន **៩២.៥%** និងបើធៀបទៅនឹងផែនការសកម្មភាពប្រចាំឆ្នាំសម្រេចបាន **៩៤.៦%** ដែលមានសកម្មភាពចម្បងៗចំនួន ០៦ គឺ៖

1. ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)
2. ការអភិវឌ្ឍភូមិចម្រុះ
3. ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
4. ការគាំទ្រសកម្មភាពអប់រំក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងសហគមន៍
5. ការគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
6. ការគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ មាន ០២ សកម្មភាពគឺ
   - ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ
   - ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

#### ក. ការពង្រឹងសមត្ថភាព គ.អ.ភ

- គាំទ្រដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ១១ ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ បានចំនួន ៣០ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦០០ នាក់ ស្រី ២១១ នាក់ មកពី ១៦៩ ភូមិ។
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានចុះពង្រឹងតួនាទី ភារកិច្ច គ.អ.ភ បានចំនួន ៦៩ វគ្គ មានសិក្ខាកាមសរុបចំនួន ២ ១៩២ នាក់ ស្រី ៧៧៤ មកពី ៣៧៣ ភូមិ។

#### ខ. ការធ្វើបច្ចុប្បន្នភាព គ.អ.ភ

- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត បានធ្វើបច្ចុប្បន្នភាពបានចំនួន ៥៨៣ ភូមិ ២៩ ឃុំ ៨៣ ស្រុក ហើយមានសមាជិក គ.អ.ភ សរុបចំនួន ៤ ២៨៥ នាក់ ស្រី ១ ៣១៧ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ១ ៥៣៤ ភូមិ ភូមិមានអង្គការគាំទ្រចំនួន ២១០ ភូមិ។

# វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ





# សកម្មភាព គ.អ.ភ ក្នុងការចូលរួមអភិវឌ្ឍន៍ភូមិ





## ២. ការអភិវឌ្ឍភូមិចម្រុះ

គាំទ្រសកម្មភាពអភិឌ្ឍន៍ភូមិចម្រុះរួមមាន កូនឈើហូបផ្លែ ពូជបន្លែចម្រុះ និងស្រះគ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តចំនួន ០៥ ខេត្ត (សៀមរាប ត្បូងឃ្មុំ កំពត ព្រៃវែង និងស្ទឹងត្រែង) រួមមាន៖

- កូនឈើហូបផ្លែចម្រុះចំនួន ៤ ០០០ ដើម ដល់គ្រួសារសរុបចំនួន ៥០០ គ្រួសារ
- ពូជបន្លែចម្រុះចំនួន ៩ ០០០ កញ្ចប់ ដល់គ្រួសារសរុបចំនួន ៥០០ គ្រួសារ
- ស្រះគ្រួសារចំនួន ១០០ ស្រះ ដល់គ្រួសារសរុបចំនួន ១០០ គ្រួសារ។

# សកម្មភាពផ្តល់ជូន កូនឈើហូបផ្លែ ពូជបន្លែចម្រុះ និងស្រះគ្រួសារដល់ប្រជាពលរដ្ឋក្នុងសហគមន៍





## ៣. ការបង្កើនសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ

- បើកវគ្គបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត បានចំនួន ០៥ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១០០ នាក់ ស្រី ៨២ នាក់
- ផ្តល់ពូជបន្លែចម្រុះដល់គ្រួសារសហគមន៍ចំនួន ៣១៥ គ្រួសារ ក្នុងខេត្តគោលដៅចំនួន ០២ គឺ សៀមរាប (២១០ គ្រួសារ) និងខេត្តកែប (១០៥ គ្រួសារ)
- ផ្តល់សម្ភារធ្វើរោងជីកំប៉ុស្តដល់គ្រួសារសហគមន៍ចំនួន ៣១៥ គ្រួសារ ក្នុងខេត្តគោលដៅចំនួន ០២ គឺសៀមរាប (២១០ គ្រួសារ) និងខេត្តកែប (១០៥ គ្រួសារ)។

# បណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត ដល់គ្រួសារសហគមន៍





## ៤. ការអប់រំក្រៅប្រព័ន្ធ

បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ បានចំនួន ០៥ វគ្គ ដែលមានចំនួនសរុប ១០០ នាក់ ស្រី ៣៤ នាក់ មកពី ១០ ភូមិ ក្នុងនោះ៖

- ខេត្តប៉ៃលិន ចំនួន ០២ វគ្គ មានសិក្ខាកាមសរុបចំនួន ៤០ នាក់ ស្រី ១២ នាក់ មកពី ០៤ ភូមិ
- ខេត្តបន្ទាយមានជ័យ ចំនួន ០៣ វគ្គ មានសិក្ខាកាមសរុបចំនួន ៦០ នាក់ ស្រី ២២ នាក់ មកពី ០៦ ភូមិ។

# សកម្មភាព វគ្គបណ្តុះបណ្តាលស្តីពី ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍






## ៥. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ

- បានបើកវគ្គបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌលស្តីពី បច្ចេកទេសផលិតសាប៊ូ ការគ្រប់គ្រងផលិតផលក្រោយប្រមូលផល ការអភិវឌ្ឍសហគមន៍ ការដាំដំណាំ និងការចិញ្ចឹមសត្វ បានចំនួន ០៩ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៣៤០ នាក់ ស្រី ១៦១ នាក់។
- បានសហការអនុវត្តគម្រោងរវាងអង្គការម៉ារីយ៉ាអ៊ីនធើណាសិនណាល់ (Merry Year International) ដើម្បីធ្វើការបណ្តុះបណ្តាលបន្ថែមបានចំនួន ០៧ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ១៣៩ នាក់ ស្រី ៥៧ នាក់។

# វគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ







# I. សមិទ្ធផលសម្រេចបាន

## ៦. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលនៅក្រៅមជ្ឈមណ្ឌលស្តីពី ជួសជុលអណ្តូងស្នប់ ដាំដំណាំ និងចិញ្ចឹមសត្វ បានចំនួន ៣៤ វគ្គ មានសិក្ខាកាមសរុបចំនួន ៦៨០ នាក់ ស្រី ២៨៣ នាក់ ក្នុងនោះ៖

- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន ១៩ វគ្គ សិក្ខាកាមចំនួន ៣៨០ នាក់ ស្រី ១៩៧ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន ១៥ វគ្គ សិក្ខាកាមចំនួន ៣០០ នាក់ ស្រី ៨៦ នាក់។

# វគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ







# I. សមិទ្ធផលសម្រេចបាន

## ៧. គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

- គម្រោង "**ការកសាងភូមិសន្តិភាព តាមរយៈការអភិវឌ្ឍសហគមន៍ជនបទចម្រុះ**" (Building Peace Village Through Integrated Rural Community Development) មានរយៈអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ជាមួយនឹងថវិកាសរុបចំនួន ១០ 000 000 ដុល្លារអាមេរិក តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការកូរ៉េ (KOICA) ដែលនឹងអនុវត្តគម្រោងនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន។ គម្រោងមានគោលបំណង លើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អាទិភាពដល់សហគមន៍ជនបទ បង្កើននិរន្តរភាពប្រាក់ចំណូលកសិកម្ម និងអភិបាលកិច្ចល្អនៃការអភិវឌ្ឍជនបទ។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង បង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោងចុះសិក្សាលទ្ធភាពដើម្បីជ្រើសរើសភូមិគោលដៅអនុវត្តគម្រោង និងកំពុងដំណើរការជ្រើសរើសក្រុមការងារគ្រប់គ្រងគម្រោង។

# គម្រោង "ការកសាងភូមិសន្តិភាព តាមរយៈការអភិវឌ្ឍសហគមន៍ជនបទចម្រុះ"

## ( Building Peace Village Through Integrated Rural Community Development )






## ៧. គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

- គម្រោង **"ភូមិគំរូចលនាភូមិថ្មី"** (Saemaul Undong Model Villagers Project) មានរយៈអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ជាមួយនឹងថវិកាសរុបចំនួន ៩០០ ០០០ ដុល្លារអាមេរិក តាមរយៈមជ្ឈមណ្ឌលចលនាភូមិថ្មីកូរ៉េ ដែលនឹងអនុវត្តគម្រោងនៅភូមិចំនួន ០៤ ក្នុងឃុំព្រៃរំដួល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ គម្រោងមានគោលបំណង លើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អំណាចដល់សហគមន៍ជនបទ បង្កើននិរន្តរភាពកសិកម្ម និងការពង្រឹងសមត្ថភាព។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង បង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោង និងបានរៀបចំសំណើផែនការសកម្មភាពអនុវត្តសកម្មភាពរបស់ភូមិ។

# គម្រោង “ភូមិគំរូចលនាភូមិថ្មី”

## ( Saemaul Undong Model Villagers Project )



## II. បញ្ហាប្រឈម

- ជីវភាពខ្វះខាតធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនចំណាកស្រុក ដែលឱ្យប៉ះពាល់ដល់ដំណើរការនៃការ
- អនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋាន
- ថវិកាសម្រាប់បណ្តុះបណ្តាលពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅឡើយ
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនប្រើប្រាស់ គ.អ.ភ ហើយបានបង្កើត និងប្រើប្រាស់ជនបង្គោលផ្សេងៗ
- ពុំសូវមានសមាសភាព គ.អ.ភ ជាស្ត្រី ដែលសារាចរណែនាំ ជំរុញសមាសភាពជាស្ត្រីចូលរួមឱ្យបានច្រើន
- សកម្មភាពគាំទ្រការអភិវឌ្ឍភូមិចម្រុះ និងសន្តិសុខស្បៀង ដែលមានការផ្តល់ពូជរុក្ខជាតិ ពូជសត្វស្រះត្រួសារ និងសម្ភាររោងជីកំប៉ុស្តជាដើម ត្រូវបានដាក់ក្នុងផែនការលទ្ធកម្មរួមរបស់ក្រសួង ធ្វើឱ្យសកម្មភាពនេះពិបាកក្នុងការអនុវត្ត ឬមិនអាចអនុវត្តបាន។

## III. មេរៀន និងបទពិសោធន៍

### ចំណុចខ្លាំង៖

- មានប្រកាសអន្តរក្រសួងលេខ ២ ៣៩១ ប្រ.ក ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ និងសារាចរណែនាំលេខ ០០៩៨ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីប្រើប្រាស់ គ.អ.ភ ជាយន្តការនៃការអភិវឌ្ឍ
- គ.អ.ភ ដែលបានទទួលការបណ្តុះបណ្តាលរួចហើយ មានការយល់ច្បាស់ពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ខ្លួន
- គ.អ.ភ បានជួយថែទាំនូវបណ្តាសមិទ្ធផលរួមនានាក្នុងភូមិ ជួយតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងផ្សេងៗ នៅក្នុងភូមិ
- មានការគាំទ្រដល់ការអភិវឌ្ឍចម្រុះ ដល់គ្រួសារក្នុងភូមិគោលដៅនូវ ពូជបន្លែចម្រុះ កូនឈើហូបផ្លែ ស្រះគ្រួសារ និងសម្ភារធ្វើជីកំប៉ុស្ត
- មានមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ ជាកន្លែងសម្រាប់ធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពនូវជំនាញវិជ្ជាជីវៈ/ជំនាញមូលដ្ឋាន ការដាំដំណាំ ការចិញ្ចឹមសត្វ ភាពជាអ្នកដឹកនាំសហគមន៍ និងចលនាភូមិថ្មី ដល់ប្រជាពលរដ្ឋ និងអ្នកដឹកនាំក្នុងសហគមន៍។

## III. មេរៀន និងបទពិសោធន៍

**ចំណុចខ្វះខាត៖**

- ការកំណត់តម្រូវការអាទិភាពភូមិ និងរៀបចំផែនការអភិវឌ្ឍន៍ភូមិរបស់ គ.អ.ភ នៅមានកម្រិត
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- គ.អ.ភ មួយចំនួន មិនទាន់មានសមត្ថភាពកៀរគរធនធានក្នុង និងក្រៅភូមិ សម្រាប់អភិវឌ្ឍន៍ភូមិ
- ការគាំទ្រការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងសម្រាប់ចុះតាមដានសកម្មភាពរបស់ គ.អ.ភ របស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត មានកំណត់
- សមាជិកមួយចំនួនមិនទាន់យល់ច្បាស់ពីតួនាទី ភារកិច្ចរបស់ គ.អ.ភ
- គាំទ្រការអភិវឌ្ឍភូមិចម្រុះ និងសន្តិសុខស្បៀង ដែលមានការផ្តល់ពូជរុក្ខជាតិ ពូជសត្វ ស្រះគ្រួសារ និងសម្ភាររោងដីកំប៉ុស្ត ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ
- ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពនូវជំនាញវិជ្ជាជីវៈ/ជំនាញមូលដ្ឋាន ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ

# III. មេរៀន និងបទពិសោធន៍

**សំណូមពរ៖**

- បង្កើនថវិកាសម្រាប់បណ្តុះបណ្តាល គ.អ.ភ
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងអង្គការដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលកំពុងតែអនុវត្តគម្រោងនៅតាមភូមិគោលដៅ ប្រើប្រាស់ គ.អ.ភ អោយអស់ពីលទ្ធភាព
- ក្រសួងអភិវឌ្ឍន៍ជនបទ អង្គការជាតិ អន្តរជាតិ ភ្នាក់ងារអភិវឌ្ឍន៍ជនបទ គាំទ្រទាំងស្មារតី សម្ភារ និងថវិកាដើម្បីឱ្យមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត មានលទ្ធភាពពង្រឹងសមត្ថភាព និងប្រើប្រាស់ គ.អ.ភ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងដំណើរការអភិវឌ្ឍន៍ជនបទដោយមានការចូលរួម
- គាំទ្រឱ្យមានស្នាក់ការភូមិសម្រាប់ គ.អ.ភ
- គាំទ្រឱ្យមានការអភិវឌ្ឍភូមិគំរូ។

# សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍសហគមន៍ គឺជាផ្នែកមួយនៃសកម្មភាពសកម្មភាពរួម ឬវិស័យមួយរួមចំណែកក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទ និងការកាត់បន្ថយគម្លាតរវាងតំបន់ជនបទ និងទីក្រុងទាក់ទងជាមួយលក្ខខណ្ឌទូទៅក្នុងជីវភាពសង្គមប្រចាំថ្ងៃ។

ក្នុងនោះដែរ ក្រោមការដឹកនាំគាំទ្រ និងចង្អុលបង្ហាញពី **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ក៏ដូចជាថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីឆ្លើយតបទៅនឹងទស្សនវិស័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ **“សហគមន៍មានលក្ខខណ្ឌជីវិតរស់នៅសមរម្យប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានសមត្ថភាពអាចគ្រប់គ្រងចាត់ចែង និងដឹកនាំការងារអភិវឌ្ឍន៍បានដោយខ្លួនឯង”** នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ បានប្រើប្រាស់ថវិកាតាមកម្មវិធី និងកំណត់នូវសូចនាករច្បាស់លាស់ ហើយអនុវត្តនូវសកម្មភាពអភិវឌ្ឍន៍ចម្រុះ ដែលមានការពង្រឹងសមត្ថភាព និងការផ្តល់នូវជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីរួមចំណែកលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជននៅតាមសហគមន៍ជនបទ៕

# សូមអរគុណ !